អ៊ិនធើណេសិនណល ស្គូល អហ្វ សៀមរាប
International School of Siem Reap

សេចក្ដីជូនដំណឹង
សម្រាប់ខែធ្នូ ឆ្នាំ២០១៧

លេខ:1

លើកទី៤

សេចក្ដីជូនដំណឹងពីសាលាបឋមសិក្សាផ្នែកភាសាអង់គ្លេស

អំពីការណាត់ជួបមាតាបិតាឬអាណាព្យាបាលសិស្ស ថ្ងៃទី៤ ដល់ថ្ងៃទី៧ ខែធ្នូ

ការណាត់ជួបលោក-លោកស្រីដែលជាអាណាព្យាបាលសិស្ស ជាមួយលោកគ្រូ អ្នកគ្រូគឺកំពុងតែដំណើរការក្នុងសប្ដាហ៍នេះ ហើយការណាត់ជួបនេះគឺតែងតែធ្វើឡើងជារៀងរាល់ឆ្នាំ។ អត្ថប្រយោជន៍ជាច្រើនដែលលោក-លោកស្រីអាចទទួលបានពីការណាត់ជួបនេះ គឺដើម្បីសាកសួរព័ត៌មានអំពីការសិក្សារបស់កូនៗ ដែលបានសិក្សាកន្លងមកនៅក្នុងថ្នាក់ក៏ដូចជាសកម្មភាពរៀនផ្សេងៗនៅពេលចេញលេងផងដែរ។ ម៉្យាងវិញទៀតវាក៏ជាឱកាសល្អមួយដែលលោក-លោកស្រីអាចសួរជាសំណួរផ្ដាំផ្ញើរទៅកាន់លោកគ្រូ អ្នកគ្រូបន្ទុកថ្នាក់តែម្ដង។ នាងខ្ញុំដែលជានាយកផ្នែកបឋមអង់គ្លេសមានភាពរីករាយក្រៃលែងដែលលោក-លោកស្រីបានចូលរួមណាត់ជួបជាមួយ និងលោកគ្រូអ្នកគ្រូ។ ចំពោះមាតិបិតាដែលមិនបានមក ណាត់ជួបជាមួយលោកគ្រូ អ្នកគ្រូ សូមមេត្តាមកទំនាក់ទំនងជាមួយផ្នែករដ្ឋបាលដើម្បីឱ្យពួកគាត់ធ្វើការរៀបចំសម្រាប់ការណាត់របស់ លោក-លោកស្រី។ សូមបញ្ជាក់ថា លោកគ្រូ អ្នកគ្រូនឹងជួបជាមួយមាតាបិតាជាច្រើននាក់ទៅតាមពេលវេលាដែលបានណាត់ ដូចនេះសូមលោក-លោកស្រីមេត្តាមកឱ្យបានទាន់ពេលវេលាទៅតាមម៉ោងដែលបានជ្រើសរើស ជាពិសេសដើម្បីជៀសវាងការរង់ចាំយូរ ពីមាតាបិតាដែលត្រូវជួបបន្ទាប់។

អំពីការប្រគុំតន្ត្រីបុណ្យណូអែល ថ្ងៃទី១៥ ខែធ្នូ វេលាម៉ោង៩:០០ព្រឹក

សាលាបានរៀបចំឱ្យមានកម្មវិធីបុណ្យណូអែលដែលនឹងប្រព្រឹត្តក្នុងពេលដ៏ខ្លីខាងមុខនេះ ក្នុងនោះក៏នឹងមានការសម្ដែងមួយចំនួនពីសិស្សានុសិស្សទាំងអស់គ្នាផងដែរ។ ពួកគេទាំងអស់គ្នាកំពុងតែហ្វឹកហាត់ សម ដើម្បីធ្វើការសម្ដែងជូនលោក-លោកស្រីទស្សនាក្នុងថ្ងៃពិធីបុណ្យដ៏រីករាយនេះ។ សាលានឹងផ្ញើលិខិតអំពីព័ត៌មានលំអិតនៅសប្ដាហ៍ក្រោយតាមរយៈកូនៗរបស់លោក-លោកស្រីអំពីកម្មវិធីបុណ្យណូអែល។ សម្រាប់ពេលបច្ចុប្បន្ននេះ សិស្សានុសិស្សទាំងអស់ ព្រមទាំងលោកគ្រូ អ្នកគ្រូគឺមានភាពរីករាយជាទីបំផុត ក្នុងការទន្ទឹងរងចាំជួបលោក-លោកស្រីទាំងអស់គ្នា

អំពីសប្ដាហ៍ប្រឡងកន្លងទៅ

លទ្ធផលប្រឡងនាពេលថ្មីៗនេះបានធ្វើឱ្យលោកគ្រូអ្នកគ្រូមានភាពភ្ញាក់ផ្អើល ដោយសារសិស្សទាំងអស់ធ្វើបានល្អជាការរំពឹងរបស់ពួកគាត់។ លទ្ធផលដ៏វិជ្ជមាននេះ អាចបញ្ជាក់ថា សិស្សានុសិស្សទាំងអស់ពិតជាខិតខំរៀនសូត្រគួរជាទីមោតនបំផុត។ លោក-លោកស្រីអាចពិភាក្សាជាមួយលោកគ្រូ អ្នកគ្របន្ថែមទៀតអំពីការដាក់ពិន្ទុ សិស្សប្រសិនបើមានជាសំណួរលើបញ្ហានេះ។ ព្រឹត្តិបត្រពិន្ទុ ក៏បានបញ្ជូនមកកាន់លោក-លោកស្រីកាលពីថ្ងៃចន្ទ កន្លងទៅរួចហើយដែរ។ ភ្ជាប់មកជាមួយគ្នានេះ ខាងសាលាក៏មានការណែនាំលើការកែវិញ្ញាសារដែលគោរពតាមប្រពន្ធ័ ស្តង់ដារត្រឹមត្រូវរបស់ចក្រភពអង់គ្លេស លើសពីនេះ ក៏មានជាការពន្យល់ខ្លះៗនៅក្នុងលិខិតលទ្ធផលរបស់កូនៗលោក-លោកស្រីផងដែរ។ នាងខ្ញុំសូមថ្លែងអំណរគុណលោក-លោកស្រីដែលបានជំរុញឱ្យកូនៗមកសាលាបានទាន់ពេលវេលា ពិសេសក្នុងកំឡុងសប្ដាហ៍ប្រឡង។

សិស្សថ្នាក់ទី១B កំពុងតែរកឃើញគំនិតថ្មីមួយដើម្បីបង្កើតគ្រាប់កាំជ្រួច មនុស្សយន្ត នឹងប្រភេទសត្វគួរឱ្យចាប់អារម្មណ៍ដទៃទៀត ដែលពួកគេនឹងធ្វើវាឡើងពីដបប្លាស្ទិច ។

សិស្សថ្នាក់ទី២A កំពុងរៀនធ្វើសោរត្រចៀកទ្វា ដែលអាចបត់បាន។ នេះជាប្រធានបទដែលអ្នកគ្រូដាក់ឱ្យ។ ក្រោយមក អ្នកគ្រូនឹងឱ្យសិស្សយក ទ្រឹស្ដីនេះដាក់ជាគំរូ ក្នុងការបង្កើតជាស្លាបសត្វនាគរាជ។

We are one,
But we are many.

សូមសម្តែងនិងការសាទរ ស្វាគមនដល់លោក Peter

នាងខ្ញុំសូមស្វាគមន៍លោក Peter Greener មកកាន់មុខតំណែងជានាយកសាលាវិទ្យាល័យផ្នែកអង់គ្លេស។ លោក Peter Greener បានចូលរួមជាមួយសាលាអន្តរជាតិសៀមរាបតាំងពីដើមខែសីហាឆ្នាំ២០១៧ ដោយបង្រៀនលើមុខវិជ្ជា ភូមិ នឹងប្រវត្តិវិជ្ជា។ យើងទាំងអស់គ្នាជឿជាក់ថាលោក នឹងបន្តការអភិវឌ្ឍន៍ល្អ ជាបន្តរទៅទៀត ដើម្បីឱ្យសាលាអន្តរជាតិសៀមរាបកាន់តែមានភាពលេចធ្លោរជាលំដាប់។ ជាថ្មីម្តងទៀត សូមស្វាគមន៍លោក Peter ពីបុគ្គលិកទាំងអស់នៅសាលាបឋម។

ព័ត៌មានផ្នែកកីឡា

កាលពីថ្ងៃពុធ ទី២៩ ខែវិច្ឆិកា កន្លងទៅសាលាអន្តរជាតិសៀមរាបបានបង្កើតឱ្យមានការប្រកួតកីឡាបាល់ទាត់ជាមួយសាលា Hope International នៅក្លឹបកីឡាជន់លង់។ សាលាអន្តរជាតិសៀមរាប បានបញ្ជូលក្រុមបាល់ទាត់ចំនួនបីក្រុម ពីថ្នាក់ទី២ ដល់ថ្នាក់ទី៦។ ក្រុមទាំងអស់របស់ ISSR គឺធ្វើបានល្អ ទាំងការស់ហាកាគ្នា និងភាពចេះយោគយល់អាស្រ័យដល់ក្រុមប្រកួតជាមួយគ្នា។ អ្នកទាំងអស់គ្នាមានការខិតខំប្រឹងប្រែងធ្វើការជាក្រុម ព្រមទាំងបានប្រឹងប្រែងអស់ពីកំលាំងកាយ ចិត្តក្នុងការប្រកួត។

សៀវភៅបរិច្ចាគទៅសមាគមន៍ Grace House

សៀវភៅដែលទទួលបានពីការឧបត្ថម្ភពីសំណាក់លោក-លោកស្រី គឺបានយកប្រគល់ឱ្យសមាគមន៍ Grace House កាលពីថ្ងៃទី១ ខែធ្នូ កន្លងទៅនេះ ដោយក្រុមដំណាងរបស់សាលា School Council ។ សិស្សនៅទីនោះត្រេកអរជាខ្លាំងដែលទទួលបានសៀវភៅទាំងអស់នេះ ពិសេសគឺពួកគេចូលចិត្តការឌីសាញប្រដាប់ចំណាំអានសៀវភៅ (bookmark) របស់សិស្សសាលា ISSR។ សៀវភៅទាំងនេះនឹងក្លាយជាប្រយោជន៍ជាច្រើនដល់សិស្សទាំងអស់ដែលមកសិក្សានៅទីនេះ។

សិស្សថ្នាក់ទី៤B បានធ្វើដំណើរទស្សនៈកិច្ចសិក្សាទៅតំបន់អភិរក្សសត្វមួយកន្លែងក្នុងខេត្តសៀមរាប និងសិក្សាអំពីប្រភេទសត្ត ព្រមទាំងជម្រករស់នៅរបស់ពពួកសត្វទាំងនេះ។

សិស្សថ្នាក់ទី៥A កំពុងអនុវត្តន៍កីឡាបោះបាល់ប៉ែបថ្មីក្នុងម៉ោងអប់រំកាយ។ សិស្សទាំងអស់កំពុងតែមានការចូលចិត្ត នឹងចាប់អារម្មណ៍ចំពោះកីឡាថ្មីនេះ។

សូមលោក-លោកស្រីដែលជាមាតាបិតាទាំងអស់មេត្តានាំយកអាហារសម្រន់ទាំងឡាយណាដែលមានជាសុកភាពសម្រាប់កូនៗទទួលទាន។

សាលានឹងធ្វើការឈប់សម្រាកចាប់ពីថ្ងៃសុក្រ ទី១៥ ខែធ្នូ ឆ្នាំ២០១៧ ហើយចូលរៀនវិញនៅថ្ងៃចន្ទ ទី៨ ខែមករា ឆ្នាំ២០១៨ ។

ការរៀបចំ Star of the Month

ការរៀបចំ Star of the Month ខែបន្ទាប់ដែលចាប់ផ្តើមពី**ម៉ោង ៨:០០ព្រឹក**មានដូចតទៅ៖

- **ថ្ងៃអង្គារ៍ ទី៦ ខែកុម្ភៈ** ថ្នាក់ចូលរួម Nursery ដល់ថ្នាក់ទី1 (ថ្នាក់ Reception 2B សម្តែង)
- **ថ្ងៃពុធ ទី៧ ខែកុម្ភៈ** ចូលរួមមានថ្នាក់ទី២ ដល់ទី៦ (ថ្នាក់ទី៤A សម្តែង)

សិស្សទាំងអស់កំពុងទន្ទឹងរង់ចាំការសម្តែងរបស់ពួកគេដោយរីករាយ!

សេវាកម្មមើលថែកូនៗពេលរសៀលមានចាប់ពីថ្នាក់Reception 1 និងថ្នាក់ Nursery បានកំពុងតែចាប់ផ្តើមហើយ។ ប្រសិនបើលោក-លោកស្រីមានចំណាប់អារម្មណ៍ការថែទាំពេលរសៀលសូមធ្វើការទំនាក់ទំនងមកកាន់ការិយាល័យរដ្ឋបាលសាលា។